**សកម្មភាព** ៖ និទានរឿងម្តងទៀត

**សិក្សាសង្គម**

គំនូរនិងសកម្មភាពកសាង (ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**ភាសាខ្មែរ**

ការស្តាប់ (ស្តាប់គេនិយាយ និងមានសម្ថភាពស្តាប់ដោយធ្វើតាមការណែនាំងាយៗ)។

ប្រើពាក្យសម្តីកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង (ទំនាក់ទំនងដោយប្រើពាក្យសម្តី)

**គោលបំណង**

**(ភាសាខ្មែរ)** ប្រាប់បានខ្លះៗពីដំណើររឿងតាមរយៈរូបភាពដែលបានបង្ហាញ។

ប្រាប់ឡើងវិញពីសកម្មភាពតាមដំណាក់កាល ដោយអនុវត្តតាមដំណាក់កាលណែនាំ។

ប្រាប់ចំណងជើងរឿង និងអត្ថន័យតាមរូបភាព។ និទានរឿងតាមរូបភាពស្តាប់។

**(សិក្សាសង្គម)** ប្រាប់ពីរបៀបផាត់ពណ៌ដើម្បីបង្កើតជារូបភាពផ្សេងៗ។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកពូកែអី? "

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ រូបភាពសខ្មៅក្នុងសៀវភៅមួយ (មួយសន្លឹកម្នាក់)

**ការរៀបចំ** ៖ បោះពុម្ពក្រដាសរូបភាពឱ្យក្មេងម្នាក់មួយសន្លឹកៗ។ តែប្រសិនបើមានក្មេងៗច្រើនពេកនោះ អ្នកត្រូវឱ្យក្មេង២នាក់មានក្រដាសរូបភាពដូចគ្នា។ ប៉ុន្តែឱ្យក្រដាសរូបភាពម្នាក់មួយសន្លឹកៗ។

**សេចក្តីណែនាំ៖**

ចំណាំ៖ សកម្មភាពនេះអាចលេងបានទាល់តែមានការអានសៀវភៅបានច្រើនដងតែប៉ុណ្ណោះ ប៉ុន្តែបើអត់ទេ! ត្រូវមើលសេចក្តីណែនាំមួយចំនួនដូចខាងក្រោម៖

1. ថ្ងៃនេះអ្នកគ្រូនឹងអាន**សៀវភៅ**រឿង "តើអ្នកពូកែអី? "ជាមួយកូនៗទាំងអស់គ្នា។
2. ចែកក្រដាសរូបភាពឱ្យទៅក្មេងៗម្នាក់ ១សន្លឹក ។
3. បង្ហាញរូបភាពសៀវភៅឱ្យក្មេងៗមើលទាំងអស់គ្នា។
4. សុំឱ្យក្មេងៗនិយាយប្រាប់អ្នកពីអ្វីដែលបានកើតឡើងនៅដើមសៀវភៅ។ បន្ទាប់មកទៀតអ្នកត្រូវអានទំព័រដំបូងនៃសៀវភៅរឿង។

5. នៅពេលដែលអ្នកឈប់ត្រឹមណា ក្មេងដែលមានទំព័របន្ទាប់ពីអ្នកអាននោះ ឱ្យក្មេងម្នាក់នោះឡើងទៅមុខនឹងឱ្យក្មេងម្នាក់នោះបង្ហាញរូបភាពនៅទំព័រដែលក្មេងៗកំពុងតែកាន់បន្ទាប់មកឱ្យគេនិយាយប្រាប់ពីសាច់រឿងនៅក្នុងទំព័រនោះតែម្តង។
6. សួរក្មេងៗតើមានរឿងអ្វីកើតឡើងបន្ទប់មកទៀត និងឱ្យក្មេងម្នាក់នោះ ឡើងមកលើដដែលឱ្យធ្វើដូចគ្នានឹងក្មេងទី១ តែអ្នកអាចផ្តល់ការណែនាំ ទៅកាន់ពយកគេបាន ក្នុងករណីប្រសិនបើក្មេងៗមិនចាំរឿងនោះ។
7. នៅពេលអ្នកឆ្លងកាត់រឿងរ៉ាវម្នាក់ម្តងៗ សូមសួរកុមារដែលមានរូបភាពត្រូវគ្នាឱ្យឈរក្បែរអ្នកផ្សេងនៅកន្លែងផ្សេង ទៅតាមលំដាប់លំដោយ។
8. បន្តតាមវិធីនេះរហូតដល់ក្មេងៗទាំងអស់កំពុងឈរនៅខាងមុខថ្នាក់រៀនដោយបង្ហាញសៀវភៅឱ្យត្រូវតាមលំដាប់លំដោយ។
9. អានសៀវភៅម្តងទៀត។ នៅពេលដែលអ្នកបានទៅដល់រូបភាពរបស់ក្មេងណាម្នាក់ ក្មេងនោះគួរតែអង្គុយចុះម្តងទៀត។
10. នៅពេលដែលក្មេងៗទាំងអស់កំពុងអង្គុយ ឱ្យពួកគេផាត់ពណ៌រូបភាពនោះ ។

**ការប្រែប្រួលៈ**

ប្រសិនបើអ្នកមិនបានអានសៀវភៅច្រើនដងទេនោះ គឺត្រូវធ្វើតាមការណែនាំខាងក្រោមនេះ ប្រសើជាងធ្វើតាមការណែនាំខាងលើ។

1. ត្រឹមតែបោះពុម្ពសន្លឹករូបភាព ៤ ឬ៥សន្លឹក ដោយមានរូបភាពច្បាស់ដូចនៅក្នុងរឿង ។
2. ឱ្យសន្លឹករូបភាពទៅតាមក្រុមនីមួយៗទៅតាមលំដាប់លំដោយ។
   (ឧទាហរណ៍៖ ក្មេងទី ១ក្នុងក្មេងទាំង ៦នោះទទួលបានក្រដាសលេខរាងទី១ និងក្មេងបន្ទាប់ទៀតទទួលបានក្រដាសបន្ទាប់ទៀតដូចគ្នា) ។
3. ពិភាក្សាពីរូបភាព នឹងពីអ្វីដែលពួកគេបានបង្ហាញ ។
4. អានរឿងនៅពេលអ្នកទៅដល់ផ្នែកមួយនៃសាច់រឿងជាមួយនឹងរូបភាពដែលក្មេងៗកំពុងកាន់ សូមឱ្យកុមារទាំងនោះក្រោកឈរ ហើយកាន់រូបភាពនៅពីមុខក្មេងៗ ដើម្បីអោយអ្នករាល់គ្នាបានឃើញ។
5. ប្រសិនបើក្មេងៗចង់ស្តាប់រឿងម្តងទៀតនោះ អ្នកអាចអានវាម្តងទៀតបាន និងឱ្យពួកគេទាំងអស់អង្គុយចុះនៅពេលដែលអ្នកកំពុងនិយាយពីរូបភាពរបស់ពួកគេ។
6. ប្រសិនបើក្មេងៗមិនចង់ស្តាប់រឿងម្តងទៀតទេនោះ ឱ្យក្មេងៗអង្គុយផាត់ពណ៌រូបភាពបានយ៉ាងសប្បាយ ។